# Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយភ្លាមៗ

## ក្រុមអ្នកតាមដានទន្លេមេគង្គ រាយការណ៍ពីការសង្កេតបឋមនៃផលប៉ះពាល់ពីទំនប់វារីអគ្គិសនី

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២** – គម្រោងទំនប់វារីអគ្គិសនីចំនួនពីរ តាមដងទន្លេដ៏សំខាន់ជាងគេក្នុងតំបន់អាស៊ីអគ្នេយ៍ បានបង្កឲមានផលប៉ះពាល់គួរឲកត់សម្គាល់ តែក្នុងកម្រិតមធ្យម ទៅលើរំហូរទឹក កំណកកករ និងជលផល។ នេះបើយោងតាមលទ្ធផលបឋមនៃរបាយការណ៍មួយរបស់គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) ដែលបានចេញផ្សាយកាលពីសប្តាហ៍មុន។

ជាមួយនឹងទិន្នន័យតាមដានរយៈពេលប្រមាណមួយឆ្នាំ ក្រុមអ្នកអង្កេតយល់ថា វាលឿនពេកក្នុងការធ្វើសេចក្តីសន្និដ្ឋានជាក់លាក់ណាមួយ។ ក្រុមអ្នកអង្កេតដែលមានជាតិសាសន៍ចម្រុះដែលចូលរួមដំណើរការគម្រោងសាកល្បងកម្មវិធីតាមដានបរិស្ថានរួម (Joint Environmental Monitoring programme) របស់ MRC បានវាស់ស្ទង់លើសូចនាករសំខាន់ៗទាំងប្រាំ នៃសុខមាលភាពទន្លេមេគង្គ រួមមានជលសាស្ត្រ កំណកកករ គុណភាពទឹក អេកូឡូស៊ីក្នុងទឹក និងជលផល។

តាមរយៈការសាកល្បងកម្មវិធីនេះ នៅតាមគម្រោងទំនប់វារីអគ្គិសនីថ្មីៗចំនួនពីរ នោះគឺគម្រោងដនសាហុង និងសាយាប៊ូរី MRC មានគោលដៅបង្កើតឲ្យបាននូវវិធីសាស្ត្រ និងបទដ្ឋានតាមដាននានា ដែលប្រតិបត្តិករទំនប់ទាំងអស់លើទន្លេមេនៃទន្លេមេគង្គ អាចនឹងប្រើប្រាស់អនុវត្តបាននាពេលអនាគត។

ក្នុងចំណោមការរកឃើញសំខាន់បំផុតនៃការសាកល្បងនេះ ក្រុមអ្នកតាមដាន បានសង្កេតឃើញថា លំនាំរំហូរទន្លេជារួម មិនមានការប្រែប្រួលនោះទេ។ នៅតំបន់ផ្នែកខាងលើទំនប់ សុខមាលភាពអេកូឡូស៊ីរបស់ទន្លេ មានកម្រិត "ល្អ" និង "មធ្យម" ក្នុងតំបន់អាងស្តុក ក៏ដូចជាតំបន់ផ្នែកខាងក្រោមទនៃទំនប់ទាំងពីរ។ គុណភាពទឹកស្ថិតក្នុងស្ថានភាព "ល្អ" សម្រាប់ការប្រើប្រាស់របស់មនុស្ស។ ក្នុងតំបន់អាងទំនប់ វាមិនមានភស្តុតាងបង្ហាញពីការបង្កើតស្រទាប់កករ ដែលអាចជះឥទ្ធិពលដល់ទាំងគុណភាពទឹក និងជលផលទេ។ ប៉ុន្តែនៅពេលទឹកហូរកាត់តាមទំនប់ "វាមានភស្តុតាងតិចតួច បង្ហាញពីការប្រែប្រួលគុណភាពទឹកនៅផ្នែកខាងក្រោមទន្លេ"។

នៅផ្នែកខាងក្រោមនៃគម្រោងសាយាប៊ូរី ក្នុងប្រទេសឡាវ ក្រុមអ្នកតាមដាន ក៏បានប្រទះឃើញការប្រែប្រួលកម្រិតទឹកប្រចាំថ្ងៃ ដែលអាចប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីផងដែរ។ ក៏ប៉ុន្តែ បញ្ហានេះ មិនបានកើតមាននៅផ្នែកខាងក្រោមនៃទំនប់ដនសាហុងទេ។ ក្រុមអ្នកតាមដាន ក៏បានសង្កេតឃើញលំនាំដែលបានចាប់ផ្តើមកើតមានកាលពីឆ្នាំ ២០១៨ នោះគឺការធ្លាក់ចុះនៃបណ្តុំកករ និងការផ្ទុកនូវកំណកកករ ដែលនាំមកនូវអាហាររូបត្ថម្ភចិញ្ចឹម និងធ្វើឲច្រាំងទន្លេមានលំនឹង។ ក៏ប៉ុន្តែ ការថមថយចុះនេះ "អាចនឹងបណ្តាលមកពីការបង្ខាំង ឬការកកស្ទះនៃកំណកកករ តាមតំបន់គម្រោងវារីអគ្គិសនីតាមដៃទន្លមេ និងទន្លេមេគង្គ"។

ជាចុងបញ្ចប់ ក្រុមតាមដាន ក៏បានសង្កេតឃើញពីការប្រែប្រួលខ្លះៗលើភាពចម្រុះនៃមច្ឆានៅផ្នែកខាងលើទំនប់សាយ៉ាប៊ូរី ដោយវាមានកម្រិតថេរចាប់ពីឆ្នាំ២០១៧ ដល់២០១៩ និងការធ្លាក់ចុះក្នុងឆ្នាំ២០២០។ នៅផ្នែកខាងក្រោមនៃអាងស្តុក ភាពចម្រុះនេះ នៅតែមានកម្រិតខ្ពស់។ ផ្ទុយមកវិញ ផលចាប់ ហាក់ដូចជាមានកម្រិតថេរ ដែលគេបានរាយការណ៍ថាកើនឡើងនៅឆ្នាំ២០១៧ ធ្លាក់ចុះនៅឆ្នាំ២០១៨ និង២០១៩ ហើយកើនឡើងវិញនៅឆ្នាំ២០២០។ នៅជុំវិញទំនប់ដនសាហុងវិញ ក្រុមអ្នកតាមដានបានប្រទះឃើញទិន្នន័យគួរឲ្យភ្ញាក់ផ្អើលមួយ នោះគឺ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ទិន្នផលចាប់នៅភាគខាងជើងប្រទេសកម្ពុជាបានធ្លាក់ចុះ ប៉ុន្តែវាបានកើនឡើងខ្លាំងនៅផ្នែកខាងក្រោមនៃទំនប់ទៅវិញ។

ទោះជាយ៉ាងនេះក្តី លទ្ធផលទាំងនេះ បានមកពីវដ្តតាមដានមួយប៉ុណ្ណោះ។ ក្រុមអ្នកសង្កេត JEM ស្នើឲ្យធ្វើការតាមដាន ពីរទៅបីឆ្នាំបន្ថែមទៀត ដើម្បីទាញឲ្យបាននូវ “ការសន្និដ្ឋានដ៏មុតមាំមួយ” ពីផលប៉ះពាល់នៃការអភិវឌ្ឍទំនប់វារីអគ្គិសនី និងសម្ពាធនានាបង្កើតឡើងដោយសកម្មភាពមនុស្ស។

បណ្ឌិត អានុល័ក ខិធិឃួន នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC ថ្លែងថា “យើងត្រូវដឹងពីកម្រិតនៃបញ្ហាប្រឈមរបស់យើង និងធ្វើការកំណត់ពីវិធីសាស្ត្រដែលមានប្រសិទ្ធភាពបំផុត ដើម្បីវាយតម្លៃផលប៉ះពាល់នេះ។ ខណៈដែលរបាយការណ៍នេះ បង្ហាញពីផលប៉ះពាល់ខ្លះៗនៃទំនប់វារីអគ្គិសនី វាលឿនពេកក្នុងការវាយតម្លៃថា រាល់ផលប៉ះពាល់ទាំងអស់សុទ្ធតែបណ្តាលមកពីទំនប់។ ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍផ្សេងទៀត ក៏អាចជាកត្តាផងដែរ”។

សរុបមក របាយការណ៍តាមដានបរិស្ថានរួមនេះ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងធំមួយរបស់ MRC ដែលតំណាងឲ្យបណ្តាប្រទេសជាសមាជិក រួមមានកម្ពុជា ឡាវ ថៃ និងវៀតណាម ដើម្បីសំដៅបង្កើតឲ្យមានតុល្យភាពមួយ រវាងអត្ថប្រយោជន៍សេដ្ឋកិច្ចនិងសង្គម និងផលប៉ះពាល់ ពីទំនប់វារីអគ្គិសនី មិនត្រឹមតែលើបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើក្រុមគ្រួសារនេសាទ និងកសិកររាប់លាន ដែលពឹងអាស្រ័យលើទន្លេមេគង្គសម្រាប់ការចិញ្ចឹមជីវិត។

សម្រាប់គម្រោងសាកល្បង JEM នេះ ក្រុមអ្នកតាមដាន បានធ្វើការសាកល្បងពិធីការរបស់គេ រយៈពេលប្រមាណមួយឆ្នាំ បន្ទាប់ពីការពន្យាពេលយ៉ាងយូរ បង្កដោយការរីករាលដាលនៃជំងឺកូវីដ១៩។ របាយការណ៍នេះ នឹងក្លាយជាមូលដ្ឋានគ្រឹះមួយសម្រាប់សកម្មភាពនានា ទាំងផ្នែកគោលនយោបាយ និងតាមដាននាពេលអនាគត។ ដូចដែលរបាយការណ៍ផ្ទាល់បានបញ្ជាក់ របបគំហើញទាំងនេះ អាចជាជំនួយដល់ការ “រៀបចំប្លង់ និងទីតាំងគម្រោងទំនប់វារីអគ្គិសនីនាពេលខាងមុខ ការព្យាករណ៍ពីការប្រែប្រួលនានា ពាក់ព័ន្ធនឹងប្រតិបត្តិការគម្រោង និងការអភិវឌ្ឍ ការប្រើប្រាស់ និងការវាយតម្លៃនៃយន្តការគ្រប់គ្រង និងកាត់បន្ថយផលប៉ះពាល់”។ លើសពីនេះ វាអាចផ្តល់ជា “មូលដ្ឋានមួយសម្រាប់កិច្ចពិភាក្សាបែបស្ថាបនា រវាងសហគមន៍តាមដងទន្លេ និងសមាជិករបស់ MRC”។

ក្នុងចំណោមអនុសាសន៍ជាច្រើនផ្តល់ទៅឲ្យ MRC ប្រទេសជាសមាជិក និងប្រតិបត្តិករទំនប់វារីអគ្គិសនី របាយការណ៍នេះ ស្នើថា ដើម្បីកាត់បន្ថយផលប៉ះពាល់លើជលសាស្ត្រ កំណកកករ និងជលផល ភាគីពាក់ព័ន្ធ

ទាំងអស់ខាងលើ គប្បីដាក់ស្នើជារួមនូវ “គោលដៅ ឬកំហិតនានាលើអត្រានៃបម្រែបម្រួលកម្រិតទឹក” ក្នុងទន្លេមេនៃទន្លេមេគង្គ, ប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងរួមសម្រាប់ការជូនដំណឹង, ប្រតិបត្តិរួមគ្នានូវច្រកទ្វារកម្រិតទាបសម្រាប់ចរាចរកំណាកកករ, ហើយក្នុងករណីទំនប់ដនសាហុង ធ្វើឲ្យច្រកចូលសម្រាប់ច្រកចរាចរត្រីកាន់តែជ្រៅ និងធ្វើឲ្យប្រសើរឡើងនូវច្រកប្រឡាយទាំងនេះ។

សម្រាប់គម្រោងនាពេលអនាគត របាយការណ៍ក៏បានអំពាវនាវឲ្យមាន “ការតាមដានទឹកជាប្រព័ន្ធ ក្នុងអំឡុងពេលនៃគ្រប់ដំណាក់កាលសាងសង់ និងប្រតិបត្តិការទាំងអស់ ដើម្បីចាត់វិធានសមស្រប ក្នុងករណីស្ថានភាពគុណភាពទឹកមិនល្អកើតឡើង”។

MRC ក៏កំពុងនឹងជជែកពិភាក្សាពីរបៀបដាក់បញ្ចូលការតាមដាន JEM នៅក្នុងបណ្ដាញស្នូលថ្មីសម្រាប់ការតាមដានទន្លេ ជានាឲ្យមានការតាមដានរយៈពេលយូរ ការធ្វើរបាយការណ៍ និងការគ្រប់គ្រងបែបបន្សាំ ដែលចាំបាច់ក្នុងការថែរក្សាការពារទន្លេមេគង្គនេះ។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះបំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាជាមជ្ឈមណ្ឌលប្រមូលផ្ដុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក មាស សុភគ្គ្រ មន្ត្រីឯកទេសផ្នែកការចូលរួមរបស់ភាគីពាក់ព័ន្ធ
មន្ត្រីសារព័ត៌មានបណ្ដោះអាសន្ន
លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរស័ព្ទដៃ៖ +៨៥៦-២០-៧៧៧៧៩១៦៨

###